**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតក្រុមប្រឹក្សាបច្ចេកទេសរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១១

## សម្រេច

### ជំពូកទី១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតក្រុមប្រឹក្សាបច្ចេកទេសរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិត

នៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារដែលសរសេរជាអក្សរកាត់ថា **ក.ប.ស.ស.** ដើម្បីជំរុញការអនុវត្តរបបសន្តិសុខសង្គមឲ្យកាន់តែប្រសើរឡើងថែមទៀត។

## ជំពូកទី២
## សមាសភាព និងតួនាទីភារកិច្ច

**មាត្រា ២.-**

សមាសភាពរបស់ **ក.ប.ស.ស់.** រួមមាន៖

| | | |
|---|---|---|
| -តំណាងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១រូប | ប្រធាន |
| -តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១រូប | សមាជិក |
| -តំណាងក្រសួងសុខាភិបាល | ១រូប | សមាជិក |
| -តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប | សមាជិក |
| -តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ២រូប | សមាជិក |
| -តំណាងបេឡាជាតិរបបសន្តិសុខសង្គម | ១រូប | សមាជិកអចិន្ត្រៃយ៍។ |

សមាសភាពជាក់ស្តែងត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ៣.-**

**ក.ប.ស.ស.** មានតួនាទីផ្តល់យោបល់លើផ្នែកបច្ចេកទេសជូនរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានភារកិច្ចដូចខាងក្រោម៖

ក-សិក្សាស្រាវជ្រាវអំពីការអភិវឌ្ឍន៍បច្ចេកទេសគ្រប់គ្រងនិងរបបសន្តិសុខសង្គមឲ្យបានសមស្របតាមស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច ដោយសហការជាមួយក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម។

ខ-ផ្តល់យោបល់អំពីបែបបទចាំបាច់ផ្សេងៗទៀត សម្រាប់អនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

គ-សិក្សាស្រាវជ្រាវនិងផ្តល់យោបល់អំពីជំងឺវិជ្ជាជីវៈ ដែលទាក់ទងនឹងមុខរបរប្រើកម្លាំងកាយ មុខរបរដែលប៉ះពាល់ដោយជាតិពុល និងមុខរបរដែលត្រូវអនុវត្តក្នុងលក្ខខណ្ឌឬតំបន់មានលក្ខណៈមិនប្រក្រតី ដែលនាំឲ្យកម្មករនិយោជិតកើតជំងឺផ្សេងៗ។

ឃ-សិក្សាស្រាវជ្រាវនិងផ្តល់យោបល់អំពីដំណើរការ និងការអភិវឌ្ឍន៍នៃបេឡាជាតិរបបសន្តិសុខសង្គម។

ង-ផ្តល់យោបល់ផ្នែកបច្ចេកទេសផ្សេងៗទៀតក្នុងករណីចាំបាច់ ។

**មាត្រា ៤.-**

ការផ្តល់យោបល់ផ្នែកបច្ចេកទេសនេះ ត្រូវឈរលើមូលដ្ឋានបម្រើផលប្រយោជន៍ដល់ភាគីពាក់ព័ន្ធ ដោយស្របតាមស្ថានភាពជាក់ស្តែង ។

## ជំពូកទី៣
## ការប្រព្រឹត្តទៅរបស់ ក.ប.ស.ស.

**មាត្រា ៥.-**

សមាជិក **ក.ប.ស.ស.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

បែបបទ និងរបៀបរបបការងាររបស់**ក.ប.ស.ស.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង។

**មាត្រា ៦.-**

ក្នុងករណីចាំបាច់ ប្រធាន**ក.ប.ស.ស.** មានសិទ្ធិស្នើសុំអ្នកបច្ចេកទេសឬអ្នកឯកទេសពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីផ្តល់យោបល់។

**ក.ប.ស.ស.** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា ៧.-**

**ក.ប.ស.ស.** មានលេខាធិការដ្ឋានមួយជាជំនួយការ ដែលមានទីតាំងនៅក្នុងគ្រឹះស្ថានបេឡាជាតិរបបសន្តិសុខសង្គម ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន **ក.ប.ស.ស.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

## ជំពូកទី៤
## ប្រភពធនធាន

**មាត្រា ៨.-**

**ក.ប.ស.ស.** មានកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ